**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ១០៣
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៤
**<u>សាលដីកា</u>**
លេខៈ១៤៣
ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............. ជាចៅក្រម
៣-លោក .............. ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ............... ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**
-លោក ...............

**<u>តំណាងមហាអយ្យការ</u>**
-លោក .............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ០១(ឈ) ចុះថ្ងៃទី០៩-០១-២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣១៧ ចុះថ្ងៃទី២៩-០៥-២០០២ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះសហ (ម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រីអាយុ៤១ឆ្នាំ ជាតិខ្មែរ របររកស៊ីមេផ្ទះ ទីលំនៅសព្វថ្ងៃ ភូមិបាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

ឪពុកឈ្មោះកៀវ ងួន (ស) ម្តាយឈ្មោះគ្រុយ ហៀង៩(រ)។

មានមេធាវីឈ្មោះ.......... ។

និងចុងចម្លើយឈ្មោះឧឡហ តំណាងឱ្យឈ្មោះកៅ ថុងហួរ លូស បូ៉ា និងឈ្មោះអ៊ុច សារ៉ែន (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤២ឆ្នាំជាតិខ្មែរ របរកស៊ីមន្ត្រីមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ ទីលំនៅសព្វថ្ងៃភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

ឪពុកឈ្មោះឃុាំង ឡេង(រ) ម្តាយឈ្មោះ សុន ភាព(រ) ។

**<u>កម្មវត្ថុបណ្តឹង</u>ៈ** ប្តឹងទាមទារដីស្រែទំហំ២១.៥០០ម$^{២}$

បានឃើញបណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះសហ ប្តឹងមិនសុខចិត្តពីសាលដីកាលេខ០១(ឈ) ចុះថ្ងៃទី០៩-០១-២០០៤ របស់សាលាឧទ្ធរណ៍លើ ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២១-០១-២០០០ របស់ឈ្មោះសហ ថា៖ កាលពីឆ្នាំ១៩៩២ ប្តីរបស់ខ្លួនបានទិញដីស្រែទំហំ២១.៥០០ម៉ែត្រការ៉េ ពីឃោជាកូនចៅរបស់លោកស៊ុំ សំណាង ស្ថិតនៅភូមិ យាង ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ នៅឆ្នាំ១៩៩៣ ខ្លួនបានធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ។ នៅឆ្នាំ១៩៩៤ លោកឡាយ វីរៈ បានសុំដីស្រែនោះដាក់ទាហានឈរជើងរហូតមក ដល់ឆ្នាំ១៩៩៥-១៩៩៦ ចាប់ពីពេលនោះមកខ្លួនពុំបានធ្វើស្រែទេ លុះដល់ឆ្នាំ១៩៩៩ ខ្លួនបានឃើញចុងចម្លើយទៅ ភ្ជួរធ្វើស្រែ ថែមទាំងបានជីកប្រឡាយលើកទំនប់ព័ទ្ធដីស្រែនោះទៀតផង ។ ឃើញដូចនោះខ្លួនបានទៅហាមឃាត់ តែចុងចម្លើយថា គាត់ទើបតែបានទិញពីឃោជាវរៈសេនាតូចលេខ៣៥៣ កងពលលេខ ១២ ។

បានឃើញសាលក្រមលេខ៤៩ ចុះថ្ងៃទី០៩-០៧-២០០១ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២១-០១-២០០០ របស់ដើមចោទឈ្មោះសហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-ប្រគល់ដីស្រែទំហំ២១៨ម៉ែត្រ គុណ ៥០ម៉ែត្រ ត្រូវជា១០.៩០០ម៉ែត្រការ៉េ តាមប្លង់ទីតាំងដីក្នុងលិខិតលេខ៥០ជនស-អជ ចុះថ្ងៃទី០៩-០៣-២០០១ របស់ករិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ដែលជាចំណែកដីស្រែក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខ$C_8$០៣៧៣ ចុះថ្ងៃទី២៧-១០-១៩៩៣ ដែលចុងចម្លើយឈ្មោះកៅ ថុងហួរ ឈ្មោះអ៊ុច សាវ៉ន ឈ្មោះឧឡហ និងឈ្មោះលួស បូរ៉ា បាននឹងកំពុងកាន់កាប់បច្ចុប្បន្នឱ្យចុងចម្លើយទាំងអស់ ដែលមានឈ្មោះ ឧឡហ ជាតំណាងកាន់កាប់ជាកម្មសិទ្ធិ ចាប់តាំងពីថ្ងៃដែលសាលក្រមមានអានុភាពអនុវត្តតទៅ ។

៣-បង្គាប់ឱ្យលោកប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូជ្រៅកាត់យកចំណែកដីទំហំ១០.៩០០ម៉ែត្រការ៉េ ចេញពីប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើបាស់ដីធ្លីលេខ$C_8$ ០៣៧៣ ចុះថ្ងៃទី២៧-១០-១៩៩៣ របស់ឈ្មោះឈួន ឡាក់ និងនាងសហ (ដើមចោទ) ចាប់ពីថ្ងៃដែលសាលក្រមមានអានុភាពអនុវត្តតទៅ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧,០០០រៀល ដែលដើមចោទបានបង់ទុករួចហើយចាប់ពី ថ្ងៃដែលសាលក្រមនេះ មានអានុភាពអនុវត្តតទៅ ។

តាមមាត្រា៦២,៦៣,៦៤,៦៥,៦៦,៦៨,៦៩,៧២ និងមាត្រា៧៦ នៃច្បាប់ភូមិបាល ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី ហើយបើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះសហ ចុះថ្ងៃទី១៩-០៧-២០០១ ប្តឹងមិនសុខចិត្ត លើសេចក្តីសម្រេច នៃសាលក្រមទាំងមូល ។

បានឃើញសាលដីការបៀបរបស់សាលាឧទ្ធរណ៍លខ០៨(ឈ) ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ចាត់របៀបបង្គាប់ឱ្យការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកអូរជ្រៅចុះវាស់វែងគូសប្លង់បង្ហាញទីតាំងដីទំនាស់រវាងដើមចោទឈ្មោះសហ និងចុងចម្លើយឈ្មោះឱតឡាយ ហ៊ាក លួស បូរ៉ា,អ៊ុច សារ៉ែន និងកៅ ចុងហួរ ជាថ្មីឡើងវិញ មុនសម្រេចដល់អង្គសេចក្តី ។

២-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ០១(ឈ)ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៤ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩-០៧-២០០១ របស់ឈ្មោះសហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៤៩ ចុះថ្ងៃទី០៩-០៧-២០០១ របស់តុលាការខេត្ត បន្ទាយមានជ័យ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំនួន៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន៥,០០០រៀល និងលើអាជ្ញាធរតុលាការចំនួន៥.០០០រៀល ។

៤-សាលដីតានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខរបស់ឈ្មោះសហ ស្ថិតនៅក្នុងកំណត់ច្បាប់ ។

ដើមចោទបានទទួលលិខិតបង្គាប់ឱ្យធ្វើសារណាហើយ ប៉ុន្តែពុំបានធ្វើសារណាជូនមក តុលាការកំពូលទេ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ តំណាងមហាអយ្យការអមតុលាការកំពូលថា :

-បណ្តឹងសាទុក្ខរបស់ដើមចោទស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកពិចារណា ។

-សាលដីការដ្ឋប្បវេណីលេខ០១(ឈ)ចុះថ្ងៃទី០៩-០១-២០០៤ របស់សាលាឧទ្ធរណ៍ ដែលបាន សម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យនិងសម្រេច ។

បានស្ដាប់ចម្លើយរបស់ឈ្មោះសហ ជាម្ចាស់បណ្ដឹងសាទុក្ខនៅពេលជំនុំជំរះឆ្លើយថា

-សាលាឧទ្ធរណ៍មិនពិនិត្យអំពីប័ណ្ណកម្មសិទ្ធិរបស់ខ្លួនទេ ដោយការទិញដីមានលិខិតទិញ លក់ ដី ត្រឹមត្រូវ ។ ខ្លួនមិនអាចចង្អុលបង្ហាញឱ្យអ្នកណាធ្វើដោយឯកឯងបានឡើយ ។ ការធ្វើនេះគឺមានរដ្ឋ អំណាចមូលដ្ឋានព្រមទាំងសុរិយោដីចុះទៅវាស់វែងត្រឹមត្រូវទាំងអស់ ។ នៅឆ្នាំ១៩៨៤-១៩៨៥ លោក ឡៃ វីរៈ បានមកខ្ចីដីរបស់ខ្លួនសម្រាប់ធ្វើបន្ទាយឱ្យយោធាស្នាក់នៅ ។ មន្ត្រីរាជការបានមកទិញដី បំពាន លើប្លង់របស់ខ្លួនពិតប្រាកដណាស់ តុលាការមិនដែលសួរដល់សុរិយោដីឱ្យបានច្បាស់លាស់ឡើយ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះឧឡហ ជាចុងបណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ ឆ្លើយថា៖

-មុននឹងទិញដីនេះ ខ្លួនបានក្ដាប់ប្រវត្តិដីនេះច្បាស់លាស់ ។ ពីមុនដីនេះជាតំបន់ព្រៃសុទ្ធសាធ ដែលពុំមានប្រជាជនរស់នៅលើដីនេះឡើយ ព្រោះដីនេះជាតំបន់ក្ដៅ សម្បូរទៅដោយមីន មិនអាចឱ្យប្រជា ជនចូលមករស់នៅបានឡើយ គឺមានតែក្រុមគ្រួសាររបស់កងទ័ពដែលស្នាក់នៅទីនោះ ហើយខ្លួនបានសួរ ដល់ភូមិ ឃុំទាំងអស់ហើយការទិញនេះគឺមានរដ្ឋអំណាចដឹងឮទាំងអស់ ហើយមានកងវរៈសេនាតូច ដែល បានចូលរួមដែរ ហើយមុននេះដីស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកស្វាយ រឿម ហើយខ្លួនបានកាន់ កាប់ តាំងពីបានផ្ទេរពីលោកស្វាយ រឿម មកម្ល៉េះ ។

ការលើកឡើងថាលោក ឡៃ វីរៈ បានទៅខ្ចីដីរបស់គាត់មកឱ្យកងទ័ពនេះ ជាពាក្យមិនពិតឡើយ ហើយពុំមានភស្តុតាងណាបញ្ជាក់ច្បាស់លាស់ឡើយ ។ ដីនេះប្រជាជនចាប់មករស់នៅតាំងពីឆ្នាំ១៩៨៧ តែសុទ្ធតែជាគ្រួសារកងទ័ពប៉ុណ្ណោះ ។ ក្រោយមកក៏មានការបែងចែកពីអង្គភាពឱ្យប្រជាជនក្រុមគ្រួសារ ទ័ពតាមភាពជាក់ស្ដែង ដូច្នេះតាមការបញ្ជាក់នេះ ដីនេះប្រាកដជារបស់ប្រជាជនទាំងនោះត្រឹមត្រូវទាំង អស់ ។

មេធាវីរបស់ដើមចោទធ្វើសេចក្ដីសន្និដ្ឋានថា

-នៅឆ្នាំ១៩៩២ កូនក្ដីខ្លួនបានទិញដីនេះពីកងទ័ពចំនួន១៤នាក់ ។ នៅឆ្នាំ១៩៩៣ បានធ្វើលិខិត កាន់កាប់ដីធ្លី ដែលមានប្រធានសុរិយោដីខេត្ត ចេញប័ណ្ណត្រឹមត្រូវ ។ ក្រោយមក លោកឡៃ វីរៈ បានមកខ្ចី ដីពីកូនក្ដីខ្លួនធ្វើជាបន្ទាយសម្រាប់បោះទីតាំងទ័ព ។ នៅឆ្នាំ១៩៩៩ ឈ្មោះស្វាយ រឿម ដែលជាកូនរបស់ លោកឡៃ វីរៈ បានយកដីនេះទៅលក់ឱ្យលោកឧឡហ ។ ពេលកូនក្ដីខ្លួនទិញដីនេះហើយ កូនក្ដីខ្លួនមិន បានទៅបោះទីតាំងនៅលើដីនោះបានឡើយ ព្រោះពេលនោះជាតំបន់អសន្តិសុខ ។

តាមប្លង់នេះបង្ហាញឱ្យឃើញថា កូនក្ដីខ្លួនមានសិទ្ធិកាន់កាប់ដីនេះតាមច្បាប់ ។

ខ្លួនសំណូមពរឱ្យប្រគល់ដីទំនាស់នេះមកកូនក្ដីខ្លួនវិញ តាមការបញ្ជាក់លើប័ណ្ណកម្មសិទ្ធិ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះសហ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការអះអាងរបស់ដើមចោទថា ខ្លួនបានទិញដីទំនាស់នេះ ពីកូនចៅរបស់លោកស៊ុំ សំណាង ចំនួន១៤នាក់ ដែលខ្លួនមិនស្គាល់ឈ្មោះ ព្រមទាំងបានធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីរួចហើយ ហើយថាលោកឡៃ វីរៈ បានខ្ចីដីនេះយកទៅប្រើប្រាស់បណ្តោះអាសន្ននោះ ពុំមានភស្តុតាងណាដែលអាចឱ្យតុលាការជឿបានឡើយពីព្រោះថា.តាមការឆ្លើយបំភ្លឺរបស់លោកស៊ុំ សំណាង ថាខ្លួនពុំមានសមត្ថកិច្ចបែងចែកដីក្រៅពីដីនៅទីប្រជុំជនប៉ោយប៉េតឡើយ ។

.ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីរបស់ដើមចោទ ចេញនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៣ មុនកំណត់ហេតុអង្កេតវាស់វែងដីដែលធ្វើនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៣ ។

.តាមការឆ្លើយបំភ្លឺ របស់លោកឡៃ វីរៈ ថា ខ្លួនពុំបានខ្ចីដីពីបុគ្គលណាឬពីឈ្មោះឈួន ឡាក់ និងឈ្មោះសហ ឡើយ ។ ប្រសិនបើមានការខ្ចីមែន ហើយដើមចោទទើបប្តឹងនៅថ្ងៃទី២១-០១-២០០០ នោះដើមចោទថ្លោះសិទ្ធិទាមទារ តាមមាត្រា២៥ នៃក្រឹត្យ ច្បាប់លេខ៣៨ ក្រច. ។

-យល់ឃើញថាឈ្មោះ ស្វាយ រឿម បានកាន់កាប់ដីទំនាស់នេះ និងបង្កបង្កើនផលតាំងពី ឆ្នាំ១៩៩៤ រហូតដល់ឆ្នាំ១៩៩៩ ទើបលក់ដីនេះឱ្យចុងចម្លើយ ហើយចុងចម្លើយបន្តបង្កបង្កើនផលរហូត មកដល់បច្ចុប្បន្ននេះ ។ ដូច្នេះ ចុងចម្លើយមានសិទ្ធិកាន់កាប់ដីនេះតាមមាត្រា៧៤ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ ។

-យល់ឃើញថា ម្ចាស់បណ្តឹងសាទុក្ខ ពុំបានធ្វើសារណាជូនមកតុលាការកំពូលតាមច្បាប់កំណត់ទេ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០១(ឈ) ចុះថ្ងៃទី០៩ ខែ មករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខគូភាគី

១-ទទួលបណ្ដឹងសាទុក្ខលេខ១៦ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះសហទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស និងគតច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ០១(ឈ) ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៩០០០រៀល ដែលក្នុងចម្លើយបានប្ដឹងគឺ :

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល

បង្គាប់ឱ្យឈ្មោះសហសងប្រាក់១៩០០០រៀល នេះទៅឱ្យឈ្មោះឧឡហ និងបង្គាប់ឱ្យឈ្មោះសហបង់ពន្ធសមាមាត្រ១ភាគរយ នៃតម្លៃដីទំនាស់ ។

៤-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ។